# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យលើកតម្កើងព្រះរាជវង្ស នៅព្រះសហគមន៍សន្តសិលា និងសន្តប៉ូល
# ភ្នំពេញថ្មី ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២០
## សន្តយ៉ូសែបជាគំរូរបស់យើង

**អត្ថបទទី១៖ កំណើតពិភពលោក ១៥,១-៦; ២១,១-៣**

«កុំខ្លាចអ្វីឡើយ! យើងនឹងធ្វើជាខែលការពារអ្នក អ្នកនឹងទទួលរង្វាន់យ៉ាងធំ»។ កណ ១៥,១

**អត្ថបទទី២៖ ហេប្រឺ ១១,៨.១១-១២.១៧-១៩**

ហេតុនេះហើយបានជាមានមនុស្សច្រើន*ឥតគណនា ដូចផ្កាយនៅលើមេឃ និងគ្រាប់ខ្សាច់នៅឆ្នេរសមុទ្រ* កើតចេញមកពីមនុស្សតែម្នាក់ ដែលចាស់ជិតស្លាប់ទៅហើយនោះផង។ ហាប ១១,១២

**ដំណឹងល្អ៖ លូកា ២,២២-៤០**

គាត់មិនត្រូវស្លាប់ ដរាបណាមិនទាន់បានឃើញព្រះគ្រីស្ត ដែលព្រះអម្ចាស់ចាត់ឲ្យមកទេនោះ។ លក ២,២៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងគោរពបុណ្យលើកតម្កើងព្រះរាជវង្ស ព្រះយេស៊ូបានកើតនៅក្នុងគ្រួសារមួយប្លែកជាមួយព្រះនាងម៉ារីនិងលោកយ៉ូសែប។ គ្រួសារដ៏វិសុទ្ធ ដែលណែនាំឲ្យព្រះសហគមន៍របស់យើង យើងបានទទួលព្រះពរដ៏ពេញលក្ខណៈណែនាំគ្រួសារនីមួយៗ។ គ្រួសារដែលមានសេចក្ដីសុខក្ដី គ្រួសារដែលមានទុក្ខលំបាកក្ដី អាចទទួលព្រះពរមួយយ៉ាងពិសេសដើម្បីបន្តធ្វើដំណើរ នៅក្នុងក្រុមគ្រួសារផ្ទាល់ខ្លួន នៅក្នុងព្រះសហគមន៍ និងនៅក្នុងសង្គមដែរ។ ថ្ងៃនេះ នៅពេលយើងនឹករលឹកដល់គ្រួសារដ៏វិសុទ្ធ យើងត្រូវការនឹកឃើញឆ្នាំនេះសម្ដេចប៉ាបប្រកាសថាជាឆ្នាំសន្តយ៉ូសែបពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១។

យើងគោរពសន្តយ៉ូសែបនៅក្នុងរបៀបពិសេស សន្តយ៉ូសែបដែលជាឪពុករបស់ព្រះយេស៊ូ សន្តយ៉ូសែបដែលជាអ្នកបម្រើរបស់ព្រះជាម្ចាស់។ សន្តយ៉ូសែបដែលជាមនុស្សសុចរិត សន្តយ៉ូសែបដែលជាប្ដីរបស់ព្រះនាងម៉ារី សន្តយ៉ូសែបដែលជាប្រជាជនធម្មតាម្នាក់រស់នៅភូមិណាសារ៉ែត។ សន្តយ៉ូសែបទៅជាគំរូសម្រាប់ព្រះសហគមន៍ ពី២០សតវត្សរ៍ជាងដែលគោរពសន្តយ៉ូសែបដែលស្រឡាញ់សន្តយ៉ូសែប ដែលផ្ញើជីវិតទៅលើសន្តយ៉ូសែប។ តាមប្រពៃណីយើងដឹងថាសន្តយ៉ូសែបណែនាំឲ្យយើងស្លាប់យ៉ាងសុខសាន្ត នៅពេលយើងទូលអង្វរព្រះជាម្ចាស់តាមរយៈលោក។

ថ្ងៃនេះជាពេលវេលា ដើម្បីត្រៀមខ្លួនចូលនៅក្នុងឆ្នាំថ្មី២០២១ យើងបានរងទុក្ខលំបាកច្រើននៅក្នុងឆ្នាំ២០២០ ទាំងនៅប្រទេសកម្ពុជាដ៏ដូចជានៅក្នុងពិភពលោក ដោយសារជំងឺកូវីដ-១៩។ យើងបានឃើញពីប៉ុន្មានថ្ងៃនៅក្នុងទ្វីបអាមេរិក នៅទ្វីបអឺរ៉ុប គេចាប់ផ្ដើមចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ សម្រាប់អ្នកដែលមិនទាន់ឆ្លងជំងឺនេះ។ ថ្ងៃនេះ ជាពេលវេលាមួយដើម្បីអធិដ្ឋាន ដោយសម្លឹងមើលគ្រួសារដ៏វិសុទ្ធ និងដើម្បីនឹកឃើញ **តើគ្រួសារដ៏វិសុទ្ធអាចបំភ្លឺជីវិតរបស់យើងដូចម្ដេចបាន?** ថ្ងៃនេះព្រះនាងម៉ារីនិងលោកយ៉ូសែប បានយកព្រះកុមារយេស៊ូដើម្បីថ្វាយទៅព្រះវិហារក្រុងយេរូសាឡឹមតាមប្រពៃណីសាសនា។

គ្រួសារដ៏សុខសាន្ត ជាគ្រួសារមួយដែលយកចិត្តទុកដាក់គោរពតាមប្រពៃណីសាសនា គោរពតាមរបៀបដែលព្រះជាម្ចាស់បង្រៀននិងណែនាំយើង ដើម្បីឲ្យគ្រួសាររស់នៅក្នុងបរិយាកាសនៃព្រះពរដែលយើងទទួលពីព្រះជាម្ចាស់។ តាមពិតប្រសិនបើយើងនឹកឃើញដល់សន្តយ៉ូសែប លោកបានស្ដាប់បង្គាប់របស់ព្រះជាម្ចាស់ជានិច្ច។ នៅពេលព្រះនាងម៉ារីមានផ្ទៃពោះមុនពេលរៀបការ នៅក្នុងចិត្តរបស់លោកយ៉ូសែបគិតថាដល់ពេលវេលា ដែលត្រូវចាកចេញពីនាងម៉ារីដោយស្ងៀមស្ងាត់ និងបន្តជីវិតនៅផ្លូវផ្សេង។ ប៉ុន្តែ ទេវទូតរបស់ព្រះជាម្ចាស់បានជួបលោកយ៉ូសែបនៅក្នុងសុបិន ដោយបានណែនាំឲ្យលោកយ៉ូសែបយល់ថា នេះជាព្រះហឫទ័យរបស់ព្រះជាម្ចាស់ កូននេះមកពីព្រះវិញ្ញាណដ៏វិសុទ្ធ សូមយកព្រះនាងម៉ារីជាភរិយាដើម្បីបង្កើតគ្រួសារដ៏សុខសាន្ត។ លោកយ៉ូសែប បានស្ដាប់បង្គាប់របស់ព្រះជាម្ចាស់ ដោយយកចិត្តទុកដាក់ធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ។ ពេលព្រះយេស៊ូប្រសូត នៅក្នុងសុបិនលោកយ៉ូសែបបានឃើញទេវទូតម្ដងទៀតដែលណែនាំឲ្យលោកដឹងថា យើងមិនអាចទៅវិញតាមផ្លូវដែលយើងបានមកទេ ដោយសារមានបញ្ហាជាមួយស្ដេចហេរ៉ូដ។ ដូច្នេះ គេបានគេចខ្លួនទៅប្រទេសអេហ្ស៊ីបមួយរយៈ គេមានទុក្ខលំបាកណាស់ដោយសារគេបានទៅប្រទេសមួយដែលគេមិនស្គាល់ ឥតមានការងារធ្វើ ឥតមានផ្ទះស្នាក់នៅ...។ ប៉ុន្តែ លោកយ៉ូសែបបានស្ដាប់បង្គាប់ព្រះជាម្ចាស់ និងយកចិត្តទុកដាក់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បីដឹកនាំជីវិតរបស់គាត់។

នេះជាចំណុចមួយ សម្រាប់យើងដែលរស់នៅលើផែនដីនេះ ដែលមានគ្រួសារ ដែលមានព្រះសហគមន៍ ដែលមានសង្គមជាគ្រួសាររបស់យើងដែរ។ **តើយើងធ្វើដូចម្ដេចយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីដឹកនាំជីវិតរបស់យើង?** ដោយដឹងថា នៅពេលយើងស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងរកឃើញសេចក្ដីសុខសាន្ត។ លោកអាប្រាហាំឥតមានសង្ឃឹមថាមានកូនទេ ប៉ុន្តែពេលព្រះជាម្ចាស់ឲ្យគាត់ចាកចេញពីប្រទេស ទោះបីគាត់ចាស់ហើយតែគាត់នៅតែទៅ។ ផ្លែនៃជំនឿរបស់គាត់ គឺគាត់បានទទួលកូនមួយដ៏ពិតប្រាកដមែន ព្រះជាម្ចាស់ប្រទាន

អ្វីៗទាំងអស់ដែលយើងត្រូវការ លុះត្រាតែយើងធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គនៅក្នុងការគោរព ស្តាប់បង្គាប់ និងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។

លោកយ៉ូសែបជាឪពុកនិងជាប្តី ជាឪពុកដែលបានយកចិត្តទុកដាក់ថែរក្សាកូនផ្ទាល់ខ្លួន ថែរក្សាគ្រួសារគាត់។ ជាប្តីរបស់ព្រះនាងម៉ារី ដោយបានយកចិត្តទុកដាក់ដើម្បីឲ្យគ្រួសារគាត់មានសេចក្តីសុខ។ នៅពេលចេញធ្វើដំណើរទៅប្រទេសអេហ្ស៊ីប និងត្រលប់មកវិញនៅភូមិណាសារ៉ែត ទោះបីយើងមិនដឹងមានអ្វីដែលកើតឡើងនៅក្នុងភូមិណាសារ៉ែតតាមគម្ពីរដំណឹងល្អ ប៉ុន្តែយើងជឿថាលោកយ៉ូសែបបានយកចិត្តទុកដាក់អប់រំកូន។ ដូចយើងបានស្តាប់ថ្ងៃនេះ "**ព្រះកុមារមានវ័យចម្រើនឡើងជាលំដាប់ មានកម្លាំងកាន់តែមាំមួនឡើង និងពោរពេញទៅដោយព្រះប្រាជ្ញាញាណ**"។ នេះដោយសារលោកយ៉ូសែបនិងនាងម៉ារី បានយកចិត្តទុកដាក់ថែរក្សាកូន អប់រំកូន ណែនាំកូនឲ្យស្គាល់អ្វីដែលល្អអ្វីដែលមិនល្អ ណែនាំឲ្យកុមារយេស៊ូស្គាល់ព្រះជាម្ចាស់។ ឪពុកម្តាយបានណែនាំឲ្យគ្រួសារនេះមានសេចក្តីសុខ នៅក្នុងការស្រឡាញ់ ថែរក្សា ការពារ ចិញ្ចឹម។

ព្រះនាងម៉ារីនិងលោកយ៉ូសែប ជាប្តីប្រពន្ធដែលបានយកចិត្តទុកដាក់ស្រឡាញ់គ្នាទៅវិញទៅមក នៅក្នុងទុក្ខលំបាកក្នុងជីវិតជាប្តីប្រពន្ធដែរ។ ប៉ុន្តែ នៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់ យើងជឿថាគាត់បានលើកលែងទោសឲ្យគ្នាទៅវិញទៅមកជានិច្ច។ នេះជាគ្រួសារដ៏វិសុទ្ធ ដែលដឹកនាំដោយលោកយ៉ូសែបជាឪពុកជាប្តី បានយកចិត្តទុកដាក់ជាមួយគ្រួសារគាត់។

លោកយ៉ូសែប ជាមនុស្សម្នាក់ដែលបានធ្វើការយ៉ាងនឿយហត់ ធ្វើការយ៉ាងយកចិត្តទុកដាក់។ នៅថ្ងៃទី០១ ខែឧសភា ជាថ្ងៃដែលយើងគោរពសន្តយ៉ូសែបជាពលករ សន្តយ៉ូសែបជាមនុស្សម្នាក់ដែលបានយកចិត្តទុកដាក់ធ្វើការងារ ទៅជាគំរូសម្រាប់ពលករ កម្មករ កសិករ និងអ្នកធ្វើការទាំងឡាយ។ គាត់បានយកចិត្តទុកដាក់អស់ពីសមត្ថភាព ដើម្បីចិញ្ចឹមគ្រួសារ។ ដូច្នេះ ពេលយើងមើលឃើញលោកយ៉ូសែប យើងត្រូវការនឹកឃើញដល់ទុក្ខលំបាកនៃជីវិតរបស់យើង ជាពិសេសសព្វថ្ងៃមានគ្រួសារមួយចំនួននៅក្នុងប្រទេសយើងបាត់បង់ការងារ គ្មានចំណូល ដោយសារឥទ្ធិពលដ៏អាក្រក់នៃជំងឺកូវីដ-១៩លើសង្គមយើងបច្ចុប្បន្ននេះ។ ប៉ុន្តែ នៅក្នុងសន្តយ៉ូសែបយើងអាចរកឃើញកម្លាំងថែមទៀត ដោយដឹងថាទោះបីមានទុក្ខលំបាកក៏ដោយ ជាពិសេសនៅពេលគាត់បានទៅប្រទេសអេហ្ស៊ីប គាត់បានខិតខំរកការងារធ្វើដើម្បីចិញ្ចឹមគ្រួសារ។ នៅពេលគាត់មកដល់ភូមិណាសារ៉ែតវិញ គាត់បានធ្វើជាជាងឈើដោយយកចិត្តទុកដាក់បង្រៀនកុមារយេស៊ូដែរ ដែលយកចិត្តទុកដាក់បែកញើសពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីចិញ្ចឹមគ្រួសារឲ្យគ្រួសារមានសេចក្តីសុខ។

លោកយ៉ូសែបជាអ្នកកែច្នៃប្រឌិតជានិច្ច លោកយ៉ូសែបជាមនុស្សម្នាក់ដែលមានគំនិតថ្មីៗជានិច្ច។ នៅពេលព្រះជាម្ចាស់ បានណែនាំឲ្យគាត់ទៅប្រទេសអេហ្ស៊ីបគាត់មិនភ័យទេ គាត់បានខិតខំទៅរកមធ្យោបាយដើម្បីដោះស្រាយបញ្ហានេះ។ នេះជាកម្លាំងមួយសម្រាប់យើងដែរ នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ យើងមិនមែនជាមនុស្សម្នាក់ដែលគាំ ប៉ុន្តែផ្ទុយទៅវិញព្រះវិញ្ញាណដ៏វិសុទ្ធបើកផ្លូវថ្មីឲ្យយើងជានិច្ច។ ជាក់ស្តែងអំឡុងពេលកូវីដ-១៩ យើងមានរបៀបថ្មីៗដើម្បីជួបជុំគ្នាជាគ្រីស្តបរិស័ទ យើងមានរបៀបប្លែកៗដើម្បីគោរពបុណ្យព្រះយេស៊ូប្រសូត។ យើងមិនអាចធ្វើធម្មតាដូចរាល់ឆ្នាំ ប៉ុន្តែនៅតាមកន្លែងនីមួយៗយើងបានយកចិត្តទុកដាក់រកមធ្យោបាយថ្មី ដើម្បីណែនាំឲ្យគ្រីស្តបរិស័ទរបស់យើងទទួលព្រះយេស៊ូប្រសូតនៅក្នុងជីវិតផ្ទាល់។ ណែនាំឲ្យព្រះសហគមន៍របស់យើងយកចិត្តទុកដាក់ជាមួយអ្នកក្រីក្រ ជាមួយអ្នកតូចតាច ជាមួយអ្នកដែលគ្មានទីពឹង ដើម្បីចែករំលែកអំណរសប្បាយនៃបុណ្យព្រះយេស៊ូប្រសូតនេះដែរ។

នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធយើងជាមនុស្សថ្មីជានិច្ច នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធឥតមានឧបសគ្គណាមួយ ដែលអាចរារាំងផ្លូវនៃព្រះពន្លឺបានទេ។ នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធយើងជាមនុស្សដែលមានសមត្ថភាព ដើម្បីកែច្នៃប្រឌិតជានិច្ច។ លោកយ៉ូសែបជាគំរូ ជាកម្លាំងសម្រាប់យើង ទោះបីយើងជួបឧបសគ្គក៏ដោយ យើងដឹងថានៅឆ្នាំ២០២១ក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដូចលោកយ៉ូសែបយើងទៅជាមនុស្សថ្មីជានិច្ច។ ដែលមានសមត្ថភាពដើម្បីកែច្នៃប្រឌិតជានិច្ច ដោយរកមធ្យោបាយផ្សេងៗ ដើម្បីបំពេញព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើងផ្ទាល់។

ថ្ងៃនេះ ខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់រួមជាមួយលោកយ៉ូសែប នៅក្នុងភាពស្ងៀមស្ងាត់ឲ្យយើងសម្លឹងមើលព្រះកុមារយេស៊ូរួមជាមួយព្រះនាងម៉ារី។ ឲ្យយើងសម្លឹងមើលព្រះកុមារយេស៊ូដែលបានចាប់កំណើតជាមនុស្ស ដែលបានប្រសូតលើផែនដីរបស់យើងនៅថ្ងៃនេះឥលូវនេះដើម្បីណែនាំឲ្យយើងទទួលការសង្គ្រោះ។ យើងមិនអាចស្ងៀមស្ងាត់ ជីវិតរបស់យើងថ្មីជានិច្ច ពីថ្ងៃដែលយើងបានគោរពព្រះយេស៊ូប្រសូតយើងដឹងថាយើងមានកម្លាំងមួយទៀត យើងមានសេចក្តីសង្ឃឹមមួយទៀតដើម្បីធ្វើដំណើរតទៅទៀត។ ប៉ុន្តែ សេចក្តីសង្ឃឹមនេះត្រូវតែទទួលការចិញ្ចឹម ការចិញ្ចឹមនៅក្នុងការអធិដ្ឋាន ការអធិដ្ឋានរបស់យើងដូចលោកយ៉ូសែប ដូចព្រះនាងម៉ារី នៅក្នុងភាពស្ងៀមស្ងាត់យើងទទួលអ្វីៗទាំងអស់ដែលយើងបានឃើញ។ ដូចនៅក្នុងវិសាលវិហារទីក្រុងយេរូសាឡឹម មាតាបិតាបានមើលរបៀបដែលលោកតាស៊ីម៉ូន របៀបដែលលោកយាយហាណ្ណា បានលើកតម្កើងកូនរបស់ខ្លួន ណែនាំឲ្យមាតាបិតាបានទទួលនៅក្នុងដួងចិត្តផ្ទាល់ខ្លួន ពោរពេញដោយអំណរសប្បាយ ព្រោះគេបានយកចិត្តទុកដាក់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។

នៅក្នុងការអធិដ្ឋាន នៅក្នុងភាពស្ងៀមស្ងាត់ យើងយកចិត្តទុកដាក់សម្លឹងមើលព្រះយេស៊ូ ដែលបានប្រសូត ដើម្បីឲ្យសង្គមរបស់យើង ឲ្យប្រទេសរបស់យើង ឲ្យព្រះសហាគមន៍របស់យើង ទៅជាពន្លឺមួយដ៏តូចប៉ុន្តែមានពន្លឺខ្លាំង នៅក្នុងភាពងងឹតនៃសង្គមបច្ចុប្បន្ននេះ ដើម្បីឲ្យយើងថែរក្សាសេចក្តីសង្ឃឹមនៅក្នុងគ្រប់កាលៈទេសៈ។

រួមជាមួយសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ យើងអធិដ្ឋានជាមួយសន្តយ៉ូសែបៈ

ឱ! សន្តយ៉ូសែបជាអ្នកមើលថែទាំព្រះសង្គ្រោះ
និងជាស្វាមីព្រះនាងព្រហ្មចារីនីម៉ារីអើយ!
ព្រះជាម្ចាស់បានប្រគល់ព្រះបុត្រាព្រះអង្គឲ្យលោក
ព្រះនាងម៉ារីបានទុកចិត្តលើលោក
ហើយព្រះគ្រីស្តក៏បានក្លាយទៅជាមនុស្សពេញវ័យជាមួយលោកផងដែរ។

ឱ! សន្តយ៉ូសែបដែលពោរពេញដោយសុភមង្គលអើយ!
សូមបង្ហាញគំរូជាឪពុកដល់យើងខ្ញុំ
ហើយដឹកនាំដំណើរជីវិតយើងខ្ញុំផង។
សូមជួយយើងខ្ញុំឲ្យទទួលព្រះណោយទាន
ធម៌មេត្តាករុណា និងចិត្តក្លាហាន
ហើយសូមជួយថែរក្សាការពារយើងខ្ញុំ
ឲ្យរួចផុតពីមារកំណាច។ អាម៉ែន៕

**រីករាយបុណ្យព្រះយេស៊ូប្រសូត**